ព្រះរាជាណាចក្រកម្ពុជា

លីមីត - អនុគមន៍

$$\lim_{x \to 0} \frac{\sin x}{x} = 1$$

សំរាប់ប្រលង

មហាវិទ្យាល័យ / វិទ្យាស្ថាន

ប.ធ

[illegible]

អារម្ភកថា

សៀវភៅ "សិក្សាអនុគមន៍ ថ្នាក់ទី ១១" នេះ អាចចាត់ទុកជាស្នាដៃទី ១ របស់អ្នករៀបរៀងដែលប្រមូលចេញពីឯកសារជាច្រើន ដើម្បីជាជំនួយក្នុងការសិក្សារបស់ប្រិយមិត្តនិងប្អូនៗ ។

ក្នុងសៀវភៅនេះ យើងមានសង្ខេបមេរៀន រូបមន្តសំខាន់ៗ ព្រមនិងដំណោះស្រាយនៃលំហាត់ ។ នៅចុងបញ្ចប់នៃសៀវភៅ យើងបានរៀបចំលំហាត់សាកល្បងវិញ្ញាសាមួយចំនួន ដែលភាគច្រើនជាលំហាត់ពិបាកៗ ហើយដែលអាចប្រកួតពិន្ទុឡើងវិញ្ញាសានេះ ដើម្បីជាមូលដ្ឋានរបស់ប្អូនៗ ។

ដោយបទពិសោធន៍នៅមានកំរិតដូចនេះ ពិតជាមានកង្វះខាតខ្លះៗពុំខាន ។ យើងខ្ញុំរង់ចាំទទួលការរិះគន់ ស្ថាបនាពីប្រិយមិត្តដោយរីករាយ ដើម្បីកែលំអសៀវភៅនេះ ពេលក្រោយកាន់តែល្អប្រសើរថែមមួយកំរិតទៀត ។

សូមប្រិយមិត្តទទួលបានជោគជ័យក្នុងការសិក្សា

ប. ជ

ទ្រឹស្តីបទនិងវិធានគណនាលីមីតខ្លះៗ

យើងបានដឹងរួចមកហើយថា លីមីតគឺជាផ្នែកសំខាន់មួយនៃវិភាគ (វិភាគគណិត) ព្រោះជាជំនួយនិងសិក្សាភាពជាប់, ដេរីវេ (ដេរីវេនិយមន័យ) ; អាស៊ីមតូត គណនាអាំងតេក្រាលកំនត់ (និយមន័យអាំងតេក្រាលកំនត់)... គេត្រូវតែប្រើលីមីត ។ ក្នុងនេះ យើងគួរតែដោះគណនាលីមីត មានរាងមិនកំនត់ទាំងឡាយ នៃលីមីត ដែលយើងតែងជួបមាន 7 គឺ

$\frac{0}{0}$; $\frac{\infty}{\infty}$; $0\times\infty$; $\infty-\infty$; 1^{∞} ; ∞^{0} ; 0^{0}

ឥឡូវនេះ យើងសូមលើកយកវិធានគណនា, ឧទាហរណ៍ និង ទ្រឹស្តីបទខ្លះៗ មកបង្ហាញ

1. វិធានគណនាលីមីតរាងមិនកំនត់ $\frac{0}{0}$

ឧបមាថា $\lim\limits_{x\to a}\frac{f(x)}{g(x)}$ មានរាងមិនកំនត់ $\frac{0}{0}$

ដើម្បីគណនាលីមីតប្រភេទនេះ គេត្រូវ

- បំបែក $f(x)$ និង $g(x)$ អោយមានកត្តា $(x-a)$; (ឬ $(x-a)^2$ ...)
- សំរួលកត្តា $(x-a)$ ដោយដើម្បីបំបាត់រាងមិនកំនត់ (ព្រោះកាលណា $x\to a$ នោះ $x\neq a$ ឬ $x-a\neq 0$ ក្នុងនេះគេអាចសំរួលកត្តា $(x-a)$ បាន)
- ជំនួសតំលៃ x ដោយ a ទៅក្នុងលីមីត

ម្យ៉ាងទៀត ដើម្បីងាយការបំបែក $f(x)$ និង $g(x)$ ជាផលគុណកត្តាមានភាពងាយស្រួល យើងសូមរំលឹកនូវលក្ខណភាពសំខាន់ៗ មួយចំនួន

$$a^2-b^2=(a-b)(a+b)$$

$$a^3-b^3=(a-b)(a^2+ab+b^2)$$

$$a^n-b^n=(a-b)(a^{n-1}+a^{n-2}b+a^{n-3}b^2+\dots+ab^{n-2}+b^{n-1});\forall n$$

$$a^3+b^3=(a+b)(a^2-ab+b^2)$$

$$a^5+b^5=(a+b)(a^4-a^3b+a^2b^2-ab^3+b^4)$$

$$a^n+b^n=(a+b)(a^{n-1}-a^{n-2}b+\dots+(-1)^p a^p b^{n-p}+\dots+b^{n-1}),\ n \text{ ជាចំនួនគត់សេស}$$

ឧទាហរណ៍ : គណនា $\lim\limits_{x\to -1}\frac{x^{2n+1}+1}{x^{2m+1}+1}$

កាលណា $x\to -1$ លីមីតនេះមានរាងមិនកំនត់ $\frac{0}{0}$

យើងបាន :

$$\lim_{x\to -1}\frac{x^{2n+1}+1}{x^{2m+1}+1}=\lim_{x\to -1}\frac{(x+1)(x^{2n}-x^{2n-1}+\dots-x+1)}{(x+1)(x^{2m}-x^{2m-1}+\dots-x+1)}$$

$$=\lim_{x\to -1}\frac{x^{2n}-x^{2n-1}+\dots-x+1}{x^{2m}-x^{2m-1}+\dots-x+1}=\frac{\overbrace{1+1+\dots+1}^{(2n+1)\text{ តួ}}}{\underbrace{1+1+\dots+1}_{(2m+1)\text{ តួ}}}=\frac{2n+1}{2m+1}$$

ដូចនេះ $\lim\limits_{x \to -1} \dfrac{x^{2n+1}+1}{x^{2m+1}+1} = \dfrac{2n+1}{2m+1}$

ឧទាហរណ៍៖ គណនា $\lim\limits_{x \to 1} \dfrac{\sqrt[n]{x}-1}{\sqrt[m]{x}-1}$

កាលណា $x \to 1$ លីមីតនេះមានរាងមិនកំណត់ $\frac{0}{0}$

យើងតាង $x = y^{mn}$; កាលណា $x \to 1$ នោះ $y \to 1$

យើងបាន៖

$$\lim_{x \to 1} \frac{\sqrt[n]{x}-1}{\sqrt[m]{x}-1} = \lim_{y \to 1} \frac{\sqrt[n]{y^{mn}}-1}{\sqrt[m]{y^{mn}}-1} = \lim_{y \to 1} \frac{y^m-1}{y^n-1}$$

$$= \lim_{y \to 1} \frac{(y-1)(y^{m-1}+y^{m-2}+\dots+y+1)}{(y-1)(y^{n-1}+y^{n-2}+\dots+y+1)}$$

$$= \lim_{y \to 1} \frac{y^{m-1}+y^{m-2}+\dots+y+1}{y^{n-1}+y^{n-2}+\dots+y+1} = \frac{\overbrace{1+1+\dots+1}^{m \text{ តួ}}}{\underbrace{1+1+\dots+1}_{n \text{ តួ}}} = \frac{m}{n}$$

ដូចនេះ $\lim\limits_{x \to 1} \dfrac{\sqrt[n]{x}-1}{\sqrt[m]{x}-1} = \dfrac{m}{n}$

---

2 វិធានគណនាលីមីតរាងមិនកំណត់ $\frac{\infty}{\infty}$

ចំពោះលីមីត $\lim\limits_{x \to \infty} \dfrac{f(x)}{g(x)}$ មានរាងមិនកំណត់ $\frac{\infty}{\infty}$

ដើម្បីគណនាលីមីតប្រភេទនេះ គេត្រូវ

- ដាក់តួមេគុណ x ដែលមានដឺក្រេខ្ពស់ជាងគេក្នុង $f(x)$ និង $g(x)$ ជាកត្តារួម
- សម្រួលកត្តានោះចោល (ព្រោះ $x \to \infty$ នោះ $x \neq 0$)
- គេឱ្យ $x \to \infty$ យើងនឹងបានលទ្ធផល

* ចំណាំ៖ ពហុធា $P(x) = a_n x^n + a_{n-1}x^{n-1} + \dots + a^{n-1}x + a^n$

កាលណា $x \to \infty$ នោះ $P(x) \simeq a_n x^n$

ឧទាហរណ៍៖ គណនា $\lim\limits_{x \to \infty} \dfrac{3x^2-7}{\sqrt{x^4-3x+4}}$

លីមីតនេះមានរាងមិនកំណត់ $\frac{\infty}{\infty}$ កាលណា $x \to \infty$

យើងបាន៖

$$\lim_{x \to \infty} \frac{3x^2-7}{\sqrt{x^4-3x+4}} = \lim_{x \to \infty} \frac{x^2\left(3-\frac{7}{x^2}\right)}{x^2\sqrt{1-\frac{3}{x^3}+\frac{4}{x^4}}} = \lim_{x \to \infty} \frac{3-\frac{7}{x^2}}{\sqrt{1-\frac{3}{x^3}+\frac{4}{x^4}}} = 3$$

ដូចនេះ

$$\lim_{x \to \infty} \frac{3x^2-7}{\sqrt{x^4-3x+4}} = 3$$

ឧទាហរណ៍៖ គណនា $\lim\limits_{x\to+\infty}\dfrac{\sqrt{x^2+x+1}+\sqrt{x^2-x+1}}{x+\sqrt{x^2+1}}$

លីមីតនេះមានរាងមិនកំណត់ $\frac{\infty}{\infty}$ កាលណា $x\to+\infty$

ដំណោះស្រាយ៖

$$\lim_{x\to+\infty}\frac{\sqrt{x^2+x+1}+\sqrt{x^2-x+1}}{x+\sqrt{x^2+1}}=\lim_{x\to+\infty}\frac{|x|\sqrt{1+\frac{1}{x}+\frac{1}{x^2}}+|x|\sqrt{1-\frac{1}{x}+\frac{1}{x^2}}}{x+|x|\sqrt{1+\frac{1}{x^2}}}$$

$$=\lim_{x\to+\infty}\frac{x\sqrt{1+\frac{1}{x}+\frac{1}{x^2}}+x\sqrt{1-\frac{1}{x}+\frac{1}{x^2}}}{x+x\sqrt{1+\frac{1}{x^2}}}$$ (ព្រោះ៖ $x\to+\infty$ នោះ $|x|=x$)

$$=\lim_{x\to+\infty}\frac{x\left(\sqrt{1+\frac{1}{x}+\frac{1}{x^2}}+\sqrt{1-\frac{1}{x}+\frac{1}{x^2}}\right)}{x\left(1+\sqrt{1+\frac{1}{x^2}}\right)}=\frac{1+1}{1+1}=\frac{2}{2}=1$$

ដូចនេះ៖

$$\lim_{x\to+\infty}\frac{\sqrt{x^2+x+1}+\sqrt{x^2-x+1}}{x+\sqrt{x^2+1}}=1$$

3. វិធានគណនាលីមីតរាងមិនកំណត់ $0\times\infty$

កាលណា $x\to a$; $f(x)\to 0$; $g(x)\to\infty$ នោះ $\lim\limits_{x\to a} f(x)\cdot g(x)$ មានរាងមិនកំណត់ $0\times\infty$ ។ ដើម្បីគណនាលីមីតប្រភេទនេះ យើងបំលែងលីមីតនោះ មានរាងមិនកំណត់ $\frac{0}{0}$ ឬ $\frac{\infty}{\infty}$ ដោយសរសេរ $f(x)\cdot g(x)$ ជារាង

+ $f(x)\cdot g(x)=\dfrac{f(x)}{\frac{1}{g(x)}}$ ឬ $f(x)\cdot g(x)=\dfrac{g(x)}{\frac{1}{f(x)}}$

(រាងមិនកំណត់ $\frac{0}{0}$ ឬ $\frac{\infty}{\infty}$)

+ អនុវត្តន៍ទ្រឹស្តីបទ L'hospital : $\lim\limits_{x\to a}\dfrac{f_1(x)}{f_2(x)}=\lim\limits_{x\to a}\dfrac{f_1'(x)}{f_2'(x)}$

+ ត្រូវចាំថា ទ្រឹស្តីបទ L'hospital អនុវត្តន៍បានតែចំពោះលីមីតដែលមានរាងមិនកំណត់ $\frac{0}{0}$ ឬ $\frac{\infty}{\infty}$ ប៉ុណ្ណោះ ។

ឧទាហរណ៍៖ គណនា $\lim\limits_{x\to0}(x.\ln x)$

កាលណា $x\to0$ លីមីតមានរាងមិនកំណត់ $0\times\infty$

ដំណោះស្រាយ៖

$$\lim_{x\to0}(x.\ln x)=\lim_{x\to0}\frac{\ln x}{\frac{1}{x}}=\lim_{x\to0}\frac{(\ln x)'}{\left(\frac{1}{x}\right)'}$$

$$=\lim_{x\to0}\frac{\frac{1}{x}}{-\frac{1}{x^2}}=-\lim_{x\to0}x=0$$

ដូចនេះ៖ $\lim\limits_{x\to0}(x.\ln x)=0$

4. វិធានគណនាលីមីតរាងមិនកំណត់ $\infty-\infty$

គេជួបប្រទះរាងមិនកំណត់ $\infty-\infty$ នៅពេល $x\to\pm\infty$ ចំពោះកន្សោមដែលត្រូវគណនាលីមីតមានរាងឫស នោះគេប្រើកន្សោមឆ្លាស់ ដើម្បីបំបាត់រាងមិនកំណត់ $\infty-\infty$ នេះ ។ និងកត្តាសាធារណ៍ដែលគេនិយមប្រើ

គេមាន: $a^2-b^2=(a-b)(a+b)$

$a^3-b^3=(a-b)(a^2+ab+b^2)$

$a^n-b^n=(a-b)(a^{n-1}+a^{n-2}b+\cdots+ab^{n-2}+b^{n-1})$

ឧទាហរណ៍ គណនា $\lim\limits_{x\to\infty}\left(\sqrt[3]{x^3+1}-x\right)$

លីមីតនេះមានរាងមិនកំណត់ $\infty-\infty$ កាលណា $x\to\infty$

យើងមាន:

$$\lim_{x\to\infty}\left(\sqrt[3]{x^3+1}-x\right)=\lim_{x\to\infty}\frac{\left(\sqrt[3]{x^3+1}-x\right)\left(\sqrt[3]{(x^3+1)^2}+x\sqrt[3]{x^3+1}+x^2\right)}{\sqrt[3]{(x^3+1)^2}+x\sqrt[3]{x^3+1}+x^2}$$

$$=\lim_{x\to\infty}\frac{(x^3+1)-x^3}{\sqrt[3]{(x^3+1)^2}+x\sqrt[3]{x^3+1}+x^2}=\lim_{x\to\infty}\frac{1}{\sqrt[3]{(x^3+1)^2}+x\sqrt[3]{x^3+1}+x^2}=0$$

ដូច្នេះ: $\lim\limits_{x\to\infty}\left(\sqrt[3]{x^3+1}-x\right)=0$

ឧទាហរណ៍: គណនា $\lim\limits_{x\to\infty}\left(\sqrt[3]{x^3+5x^2}-\sqrt[3]{x^3+8x}\right)$

យើងមាន: $\lim\limits_{x\to\infty}\left(\sqrt[3]{x^3+5x^2}-\sqrt[3]{x^3+8x}\right)$

$$=\lim_{x\to\infty}\frac{\left(\sqrt[3]{x^3+5x^2}-\sqrt[3]{x^3+8x}\right)\left[\sqrt[3]{(x^3+5x)^2}+\sqrt[3]{(x^3+5x^2)(x^3+8x)}+\sqrt[3]{(x^3+8x)^2}\right]}{\sqrt[3]{(x^3+5x)^2}+\sqrt[3]{(x^3+5x^2)(x^3+8x)}+\sqrt[3]{(x^3+8x)^2}}$$

$$=\lim_{x\to\infty}\frac{(x^3+5x^2)-(x^3+8x)}{\sqrt[3]{(x^3+5x)^2}+\sqrt[3]{(x^3+5x^2)(x^3+8x)}+\sqrt[3]{(x^3+8x)^2}}$$

$$=\lim_{x\to\infty}\frac{x^2\left(5-\frac{8}{x}\right)}{x^2\left[\sqrt[3]{\left(1+\frac{5}{x}\right)^2}+\sqrt[3]{\left(1+\frac{5}{x}\right)\left(1+\frac{8}{x^2}\right)}+\sqrt[3]{\left(1+\frac{8}{x^2}\right)^2}\right]}=\frac{5}{3}$$

ដូច្នេះ: $\lim\limits_{x\to\infty}\left(\sqrt[3]{x^3+5x^2}-\sqrt[3]{x^3+8x}\right)=\frac{5}{3}$

---

5. ករណីរាងមិនកំណត់ 1^{∞}

ដើម្បីគណនាលីមីតប្រភេទនេះ គេប្រើ

- រូបមន្ត : $\lim\limits_{\alpha\to 0}(1+\alpha)^{\frac{1}{\alpha}}=\lim\limits_{x\to\infty}\left(1+\frac{1}{x}\right)^x=e$

(e ជាគោលនៃលោការីតនេពែរ ដែល $e\approx 2,718281828$)

- ប្រើវិធី L'hospital ដែលយើងបានរៀបរាប់យ៉ាងពិស្តារក្នុងសៀវភៅ អនុគមន៍អិចស្ប៉ូណង់ស្យែល និងលោការីត ថ្នាក់ទី 10-11 និងវិញ្ញាសារាងមិនកំណត់ផ្សេងទៀត យើងពុំបានលើកយកបង្ហាញក្នុងពេលនេះទេ ព្រោះយើងបានលើកយកបង្ហាញរួចហើយក្នុងសៀវភៅ អិចស្ប៉ូ-លោការីត ម្យ៉ាងទៀតនោះរយៈពេលនេះ យើងខ្ញុំ មាននាទីសាកសួរបំពេញបន្ថែម ខ្លះៗនោះ ដូច្នេះយើងខ្ញុំ សូមលើកយកតែរូបមន្ត ដែលគណនា និង ឧទាហរណ៍ មួយចំនួន

បងប្អូនបានឃើញហើយ៖ ដំណោះស្រាយ លំហាត់ យើងសូម
ឲ្យលទ្ធភាពប្អូនៗ ដែលជាអ្នករៀនរៀន សៀវភៅនេះ
រៀបចំ៖ ម

ឧទាហរណ៍ : គណនា $\lim_{x \to \infty} \left(1 + \frac{K}{x}\right)^x$

កាលណា $x \to \infty$ លីមីតនេះមានរាងមិនកំណត់ 1^∞

យើងបាន:

$$\lim_{x \to \infty} \left(1 + \frac{K}{x}\right)^x = \lim_{x \to \infty} \left[\left(1 + \frac{K}{x}\right)^{\frac{x}{K}}\right]^K = e^K$$

ព្រោះ: $\lim_{x \to \infty} \left(1 + \frac{K}{x}\right)^{\frac{x}{K}} = e$

ដូចនេះ: $\lim_{x \to \infty} \left(1 + \frac{K}{x}\right)^x = e^K$

ឧទាហរណ៍ : គណនា $\lim_{x \to \infty} \left(\frac{x+8}{x-2}\right)^x$

យើងបាន:

$$\lim_{x \to \infty} \left(\frac{x+8}{x-2}\right)^x = \lim_{x \to \infty} \left(\frac{x-2+10}{x-2}\right)^x = \lim_{x \to \infty} \left(1 + \frac{10}{x-2}\right)^x$$

$$= \lim_{x \to \infty} \left[\left(1 + \frac{10}{x-2}\right)^{\frac{x-2}{10}}\right]^{\frac{10x}{x-2}} = e^{\lim_{x \to \infty} \frac{10x}{x-2}} = e^{10}$$

ដូចនេះ: $\lim_{x \to \infty} \left(\frac{x+8}{x-2}\right)^x = e^{10}$

ឧទាហរណ៍: គណនា $\lim_{x \to 0} \frac{\ln(1+mx)}{x}$

យើងបាន:

$$\lim_{x \to 0} \frac{\ln(1+mx)}{x} = \lim_{x \to 0} \frac{1}{x} \ln(1+mx) = \lim_{x \to 0} \ln(1+mx)^{\frac{1}{x}}$$

$$= \ln\left[\lim_{x \to 0} (1+mx)^{\frac{1}{x}}\right] = \ln\left[\lim_{x \to 0} (1+mx)^{\frac{1}{mx} \cdot m}\right]$$

$$= \ln\left[e^m\right] = m \quad (\text{ព្រោះ: } \ln e^n = n)$$

ដូចនេះ: $\lim_{x \to 0} \frac{\ln(1+mx)}{x} = m$

ឧទាហរណ៍: គណនា $\lim_{x \to 0} \frac{\ln(x+2) - \ln 2}{x}$

យើងបាន:

$$\lim_{x \to 0} \frac{\ln(x+2) - \ln 2}{x} = \lim_{x \to 0} \frac{\ln\left(\frac{x}{2} + 1\right)}{x} = \lim_{x \to 0} \frac{1}{x} \ln\left(\frac{x}{2} + 1\right)$$

$$= \lim_{x \to 0} \ln\left(1 + \frac{x}{2}\right)^{\frac{1}{x}}$$

$$= \ln\left[\lim_{x \to 0} \left(1 + \frac{x}{2}\right)^{\frac{1}{x}}\right] = \ln\left[\lim_{x \to 0} \left(1 + \frac{x}{2}\right)^{\frac{2}{x} \cdot \frac{1}{2}}\right]$$

$$= \ln\left[e^{\frac{1}{2}}\right] = \frac{1}{2}$$

ដូចនេះ: $\lim_{x \to 0} \frac{\ln(x+2) - \ln 2}{x} = \frac{1}{2}$

៦. លីមីតនៃអនុគមន៍ត្រីកោណមាត្រ កាលណា $x \to 0$

(x គិតជារ៉ាដ្យង់)

ដើម្បីគណនាលីមីតរាងមិនកំណត់នៃអនុគមន៍ត្រីកោណមាត្រកាលណា $x \to 0$ គេប្រើរូបមន្តខាងក្រោម

$$\lim_{x\to 0} \frac{\sin x}{x} = \lim_{x\to 0} \frac{x}{\sin x} = 1$$

ទូទៅ:

$$\lim_{u\to 0} \frac{\sin u}{u} = \lim_{u\to 0} \frac{u}{\sin u} = 1$$

$$\lim_{x\to 0} \frac{tg x}{x} = \lim_{x\to 0} \frac{x}{tg x} = 1$$

ឧទាហរណ៍: គណនា $\lim\limits_{x\to 0} \dfrac{\sin ax}{\sin bx}$ $(b \neq 0)$

លីមីតនេះមានរាងមិនកំណត់ $\frac{0}{0}$ កាលណា $x \to 0$

ដោះស្រាយ:

$$\lim_{x\to 0} \frac{\sin ax}{\sin bx} = \lim_{x\to 0} \left(\frac{\sin ax}{ax} \cdot \frac{bx}{\sin bx} \cdot \frac{a}{b} \right)$$

$$= \frac{a}{b} \left(\text{ព្រោះ } \lim_{x\to 0} \frac{\sin ax}{ax} = 1 ; \lim_{x\to 0} \frac{bx}{\sin bx} = 1 \right)$$

ដូចនេះ

$$\lim_{x\to 0} \frac{\sin ax}{\sin bx} = \frac{a}{b}$$

ឧទាហរណ៍: គណនា $\lim\limits_{x\to 0} \dfrac{tg x - \sin x}{x^3}$

លីមីតមានរាងមិនកំណត់ $\frac{0}{0}$ កាលណា $x \to 0$

ដោះស្រាយ:

$$\lim_{x\to 0} \frac{tg x - \sin x}{x^3} = \lim_{x\to 0} \frac{tg x (1 - \cos x)}{x^3}$$

$$= \lim_{x\to 0} \frac{tg x \cdot 2\sin^2 \frac{x}{2}}{x^3} \quad \left(\text{ព្រោះ: } 1 - \cos x = 2\sin^2 \tfrac{x}{2} \right)$$

$$= \lim_{x\to 0} \left[\frac{tg x}{x} \left(\frac{\sin \frac{x}{2}}{\frac{x}{2}} \right)^2 \cdot \frac{1}{2} \right] = 1 \cdot 1 \cdot \frac{1}{2} = \frac{1}{2}$$

ដូចនេះ: $\lim\limits_{x\to 0} \dfrac{tg x - \sin x}{x^3} = \dfrac{1}{2}$

ឧទាហរណ៍: គណនា $\lim\limits_{x\to 0} \dfrac{x \sin x}{1 - \cos x}$

ដោះស្រាយ:

$$\lim_{x\to 0} \frac{x \sin x}{1 - \cos x} = \lim_{x\to 0} \frac{2x \sin \frac{x}{2} \cdot \cos \frac{x}{2}}{2\sin^2 \frac{x}{2}}$$

$$= \lim_{x\to 0} \frac{x \cos \frac{x}{2}}{\sin \frac{x}{2}} = \lim_{x\to 0} \left(\frac{\frac{x}{2}}{\sin \frac{x}{2}} \right) 2\cos \frac{x}{2}$$

$$= 1 \cdot 2 = 2$$

ដូចនេះ: $\lim\limits_{x\to 0} \dfrac{x \sin x}{1 - \cos x} = 2$

---

7. លីមីតនៃអនុគមន៍ត្រីកោណមាត្រកាលណា $x \to a$

(x គិតជារ៉ាដ្យង់)

ដើម្បីគណនាលីមីតរាងមិនកំណត់នៃអនុគមន៍ត្រីកោណមាត្រ កាលណា $x \to a$ គេត្រូវ

* តាង $x - a = u$ កាលណា $x \to a$ នោះ $u \to 0$
* ប្រើរូបមន្ត : $\lim\limits_{x \to 0} \dfrac{\sin x}{x} = \lim\limits_{x \to 0} \dfrac{x}{\sin x} = 1$

ឬគេអាចតាង $u = a - x$ ដែល $u \to 0$ កាលណា $x \to a$

ឧទាហរណ៍ : គណនា $\lim\limits_{x \to 1} (1-x) \operatorname{tg} \dfrac{\pi x}{2}$

តាង $u = 1 - x \Leftrightarrow x = 1 - u$

កាលណា $x \to 1$ នោះ $u \to 0$ ដូចនេះ:

$$\lim_{x\to 1}(1-x)\operatorname{tg}\frac{\pi x}{2} = \lim_{u\to 0} u\cdot\operatorname{tg}\left[\frac{\pi}{2}(1-u)\right] = \lim_{u\to 0} u\operatorname{tg}\left[\frac{\pi}{2}-\frac{\pi u}{2}\right]$$

$$= \lim_{u\to 0} u\operatorname{cotg}\frac{\pi u}{2} \quad \left(\text{ព្រោះ: } \operatorname{tg}\left(\frac{\pi}{2}-\alpha\right) = \operatorname{cotg}\alpha\right)$$

$$= \lim_{u\to 0}\frac{u}{\operatorname{tg}\frac{\pi u}{2}} = \lim_{u\to 0}\left(\frac{\frac{\pi u}{2}}{\operatorname{tg}\frac{\pi u}{2}}\cdot\frac{2}{\pi}\right) = 1\cdot\frac{2}{\pi} = \frac{2}{\pi}$$

ដូចនេះ: $\lim\limits_{x\to 1}(1-x)\operatorname{tg}\dfrac{\pi x}{2} = \dfrac{2}{\pi}$

ឧទាហរណ៍: គណនា $\lim\limits_{x\to\pi/4}\dfrac{\cos 2x}{\cos\frac{\pi}{4} - \cos x}$

តាង $u = \dfrac{\pi}{4} - x$ ដែល $u \to 0$ កាលណា $x \to \pi/4$

គេបាន

$$\lim_{x\to\pi/4}\frac{\cos 2x}{\cos\pi/4 - \cos x} = \lim_{u\to 0}\frac{\cos\left(\pi/2 - 2u\right)}{\cos\frac{\pi}{4} - \cos\left(\frac{\pi}{4}-u\right)} = \lim_{u\to 0}\frac{\sin 2u}{-2\sin\frac{u}{2}\cdot\sin\left(\frac{\pi}{4}-\frac{u}{2}\right)}$$

$$= \lim_{u\to 0}\frac{2\sin u\cdot\cos u}{-2\sin\frac{u}{2}\cdot\sin\left(\frac{\pi}{4}-\frac{u}{2}\right)} = \lim_{u\to 0}\frac{4\sin\frac{u}{2}\cos\frac{u}{2}\cos u}{-2\sin\frac{u}{2}\cdot\sin\left(\frac{\pi}{4}-\frac{u}{2}\right)}$$

$$= \lim_{u\to 0}\frac{-2\cos u/2\,\cos u}{\sin\left(\pi/4 - u/2\right)} = \frac{-2\cdot 1\cdot 1}{\frac{\sqrt{2}}{2}} = -2\sqrt{2}$$

ដូចនេះ: $\lim\limits_{x\to\pi/4}\dfrac{\cos 2x}{\cos\pi/4 - \cos x} = -2\sqrt{2}$

ឧទាហរណ៍: គណនា $\lim\limits_{x\to\pi/3}\dfrac{1-2\cos x}{\pi - 3x}$

តាង $u = \pi/3 - x \Leftrightarrow x = \pi/3 - u$ ដែល $u\to 0$ កាលណា $x \to \pi/3$

$$\Rightarrow \lim_{x\to\pi/3}\frac{1-2\cos x}{\pi - 3x} = \lim_{u\to 0}\frac{1-2\cos\left(\pi/3 - u\right)}{\pi - 3\left(\pi/3 - u\right)}$$

$$= \lim_{u\to 0}\frac{1-2\left[\cos\frac{\pi}{3}\cos u + \sin\frac{\pi}{3}\sin u\right]}{3u} = \lim_{u\to 0}\frac{1-2\left[\frac{1}{2}\cos u + \frac{\sqrt{3}}{2}\sin u\right]}{3u}$$

$$= \lim_{u\to 0} \frac{1-\cos u-\sqrt{3}\sin u}{3u} = \lim_{u\to 0} \frac{2\sin^2\frac{u}{2}-2\sqrt{3}\sin\frac{u}{2}\cos\frac{u}{2}}{3u}$$

$$= \lim_{u\to 0} \frac{2\sin\frac{u}{2}\left[\sin\frac{u}{2}-\sqrt{3}\cos\frac{u}{2}\right]}{3u}$$

$$= \lim_{u\to 0} \left(\frac{\sin\frac{u}{2}}{\frac{u}{2}} \cdot \frac{\sin\frac{u}{2}-\sqrt{3}\cos\frac{u}{2}}{3}\right) = 1\cdot\left(-\frac{\sqrt{3}}{3}\right) = -\frac{\sqrt{3}}{3}$$

ដូច្នេះ $\displaystyle\lim_{x\to\frac{\pi}{3}} \frac{1-2\cos x}{\pi-3x} = -\frac{\sqrt{3}}{3}$

---

* **កំណត់សំគាល់**

1. បើ $f(x) \geq g(x)\ ;\ \forall x \in]a-\varepsilon\ ;\ a+\varepsilon[$ នោះ

$$\lim_{x\to a} f(x) \geq \lim_{x\to a} g(x)$$

2. បើ $g(x) \leq f(x) \leq h(x)\ ;\ \forall x \in]a-\varepsilon\ ;\ a+\varepsilon[$

និង $\displaystyle\lim_{x\to a} g(x) = \lim_{x\to a} h(x) = \ell$ នោះគេបាន

$$\lim_{x\to a} f(x) = \ell$$

ឧទាហរណ៍ : គណនា $\displaystyle\lim_{x\to\infty} \frac{\sin x}{x}$

ដោយដឹងថា $\forall x\ :\ -1 \leq \sin x \leq 1$

$$\Rightarrow -\frac{1}{x} \leq \frac{\sin x}{x} \leq \frac{1}{x} \qquad (x\neq 0)$$

$$\Rightarrow \lim_{x\to\infty}\left(-\frac{1}{x}\right) \leq \lim_{x\to\infty} \frac{\sin x}{x} \leq \lim_{x\to\infty} \frac{1}{x}$$

$$\Leftrightarrow\ 0 \leq \lim_{x\to\infty} \frac{\sin x}{x} \leq 0$$

ដូច្នេះ $\displaystyle\lim_{x\to\infty} \frac{\sin x}{x} = 0$

ភ្នំពេញ ថ្ងៃទី 02.05.1989

.ស. ឃ. ស.

សន្និដ្ឋានទ្រឹស្តីបទទូទៅលើលីមីត

ទ្រឹស្តីបទ ១

បើ $\lim\limits_{x\to a} f(x)=l$; $\lim\limits_{x\to a} g(x)=m$; $\lim\limits_{x\to a} h(x)=n$

នោះគេបាន

$$\boxed{\lim_{x\to a}\left[f(x)+g(x)-h(x)\right]=l+m-n}$$

ឧទាហរណ៍ : គណនាលីមីត : $\lim\limits_{x\to 1}\left(x+2-\frac{1}{x}\right)$

$$\lim_{x\to 1}\left(x+2-\frac{1}{x}\right)=\lim_{x\to 1}x+\lim_{x\to 1}2-\lim_{x\to 1}\frac{1}{x}$$

$$=1+2-1$$

ដូចនេះ $\lim\limits_{x\to 1}\left(x+2-\frac{1}{x}\right)=\underline{2}$

ទ្រឹស្តីបទ ២

បើ $\lim\limits_{x\to a} f(x)=l$; $\lim\limits_{x\to a} g(x)=m$, $\lim\limits_{x\to a} h(x)=n$

នោះគេបាន

$$\boxed{\lim_{x\to a}\left[f(x)\cdot g(x)\cdot h(x)\right]=l\cdot m\cdot n}$$

ឧទាហរណ៍ : គណនាលីមីត $\lim\limits_{x\to 3} 5x^2$

$$\lim_{x\to 3}5x^2=\lim_{x\to 3}5\left(\lim_{x\to 3}x\right)^2=5\cdot 9=\underline{45}$$

ករណីពិសេស

$$\boxed{\begin{array}{l}
* \ \lim\limits_{x\to a}\left[f(x)\right]^n=\left[\lim\limits_{x\to a}f(x)\right]^n=l^n\ ;\ n\in\mathbb{Q} \\
* \ \lim\limits_{x\to a}\lambda f(x)=\lambda\lim\limits_{x\to a}f(x)\ ;\ \lambda \text{ ថេរ} \\
* \ \lim\limits_{x\to a}\sqrt{f(x)}=\sqrt{\lim\limits_{x\to a}f(x)}\ ;\ f(x)\geq 0\Rightarrow\lim f(x)\geq 0
\end{array}}$$

ឧទាហរណ៍ : គណនាលីមីត

1. $\lim\limits_{x\to 2}\sqrt{2x+3x^2}$

$$\lim_{x\to 2}\sqrt{2x+3x^2}=\sqrt{\lim_{x\to 2}2x+3x^2}=\sqrt{\lim_{x\to 2}2x+\lim_{x\to 2}3x^2}$$

$$=\sqrt{4+12}=4$$

2. $\lim\limits_{x\to 2}4x^3$

$$\lim_{x\to 2}4x^3=4\lim_{x\to 2}x^3=4\cdot 8=32$$

3. $\lim\limits_{x\to 1}\left(5x^2+x-\sqrt{4x}\right)$

$$\lim_{x\to 1}\left(5x^2+x-\sqrt{4x}\right)=\lim_{x\to 1}5x^2+\lim_{x\to 1}x-\lim_{x\to 1}\sqrt{4x}$$

$$=5+1-2=4$$

ទ្រឹស្តីបទ៣

បើ $\lim\limits_{x\to a}(f(x)) = l$

ក. $\lim\limits_{x\to a}\dfrac{1}{f(x)} = \dfrac{1}{l}$, កាលណា $l \neq 0$

ខ. $\lim\limits_{x\to a}\dfrac{1}{f(x)} = 0$, កាលណា $l \to \pm\infty$

គ $\lim\limits_{x\to a}\dfrac{1}{f(x)} = +\infty$, កាលណា $l \to 0^+$

ឧទាហរណ៍ : គណនាលីមីត $\lim\limits_{x\to 0}\dfrac{2x+4}{x}$

$$\lim_{x\to 0}\frac{2x+4}{x} = \lim_{x\to 0} 2 + \lim_{x\to 0}\frac{4}{x} = 2+\infty = \infty$$

ទ្រឹស្តីបទ4

បើ $\lim\limits_{x\to a} f(x) = l$; $\lim\limits_{x\to a} g(x) = m.$

យើងបាន

$$\boxed{\lim_{x\to a}\frac{f(x)}{g(x)} = \frac{\lim\limits_{x\to a} f(x)}{\lim\limits_{x\to a} g(x)} = \frac{l}{m}} \quad m \neq 0$$

ករណីពិសេស

- $\lim\limits_{x\to a}\dfrac{f(x)}{g(x)} = 0$, កាលណា $l \neq 0$ ហើយ $m \to \infty$

$$\lim_{x\to a}\left|\frac{f(x)}{g(x)}\right| = \infty,$$ កាលណា $l \neq 0$ ហើយ $m = 0$

ឧទាហរណ៍ : គណនាលីមីត

1. $\lim\limits_{x\to 1}\dfrac{2x+3}{x-5}$

$$\lim_{x\to 1}\frac{2x+3}{x-5} = \frac{\lim\limits_{x\to 1} 2x+3}{\lim\limits_{x\to 1} x-5} = -\frac{5}{4}$$

2. $\lim\limits_{x\to 2}\dfrac{x+1}{x-2}$

$$\lim_{x\to 2}\frac{x+1}{x-2} = \frac{\lim\limits_{x\to 2} x+1}{\lim\limits_{x\to 2} x-2} = \frac{3}{0} = \infty$$

លំហាត់

លំហាត់ដែលមានរាងមិនកំណត់

I ចូររកលីមីតខាងក្រោម

1. $\lim\limits_{x\to -\frac{1}{3}} \dfrac{9x^2-1}{3x+1}$; 2 $\lim\limits_{x\to 1} \dfrac{x^2+x-2}{x-1}$

3 $\lim\limits_{x\to -2} \dfrac{x+2}{x^2+4x+4}$; 4 $\lim\limits_{x\to 1} \dfrac{\sqrt{x+3}-2}{x-1}$

5 $\lim\limits_{x\to 2} \dfrac{\sqrt{x^2-4}}{x^3-x^2-x-2}$; 6 $\lim\limits_{x\to 4} \dfrac{\sqrt{2x+1}-3}{\sqrt{x-2}-\sqrt{2}}$

7 $\lim\limits_{x\to 0} \dfrac{\sqrt{1+x}-\sqrt[3]{1+x}}{x}$; 8 $\lim\limits_{x\to 0} \dfrac{\sqrt{x+1}+\sqrt{x+4}-3}{x}$

9 $\lim\limits_{x\to 1} \dfrac{\sqrt[3]{x}-1}{\sqrt[3]{4x+4}-2}$; 10 $\lim\limits_{h\to 0} \dfrac{(x+h)^3-x^3}{h}$

សំរាយបញ្ជាក់

1 $\lim\limits_{x\to -\frac{1}{3}} \dfrac{9x^2-1}{3x+1}$ មានរាងមិនកំណត់ $\frac{0}{0}$

$$\frac{9x^2-1}{3x+1} = \frac{(3x+1)(3x-1)}{3x+1} = 3x-1 \quad (x \neq -\tfrac{1}{3})$$

$$\lim_{x\to -\frac{1}{3}} \frac{9x^2-1}{3x+1} = \lim_{x\to -\frac{1}{3}} (3x-1) = -2$$

$$\boxed{\lim_{x\to -\frac{1}{3}} \frac{9x^2-1}{3x+1} = -2}$$

2 $\lim\limits_{x\to 1} \dfrac{x^2+x-2}{x-1}$ មានរាងមិនកំណត់ $\frac{0}{0}$

$$\frac{x^2+x-2}{x-1} = \frac{(x-1)(x+2)}{x-1} = x+2 \quad (x \neq 1)$$

$$\lim_{x\to 2} \frac{x^2+x-2}{x-1} = \lim_{x\to 1} (x+2) = 3$$

$$\boxed{\lim_{x\to 1} \frac{x^2+x-2}{x-1} = 3}$$

3 $\lim\limits_{x\to -2} \dfrac{x+2}{x^2+4x+4}$, មានរាងមិនកំណត់ $\frac{0}{0}$

$$\frac{x+2}{x^2+4x+4} = \frac{x+2}{(x+2)^2} = \frac{1}{x+2} \quad (x \neq -2)$$

$$\lim_{x\to -2} \frac{x+2}{x^2+4x+4} = \lim_{x\to -2} \frac{1}{x+2} = \infty$$

$$\boxed{\lim_{x\to -2} \frac{x+2}{x^2+4x+4} = \infty}$$

5. $\lim\limits_{x\to 2} \dfrac{\sqrt{x^2-4}}{x^3-x^2-x-2}$, មានរាងមិនកំណត់ $\frac{0}{0}$

$$\frac{\sqrt{x^2-4}}{x^3-x^2-x-2} \quad \left(\text{មានន័យកាលណា } \mathcal{D}=]-\infty,-2[\,\cup\,]2,+\infty[\right)$$

$$=\frac{x^2-4}{(x-2)(x^2+x+1)\sqrt{x^2-4}}=\frac{x+2}{(x^2+x+1)\sqrt{x^2-4}} \quad (x\neq 2)$$

$$\lim_{x\to 2}\frac{\sqrt{x^2-4}}{x^3-x^2-x-2}=\lim_{x\to 2}\frac{x+2}{(x^2+x+1)\sqrt{x^2-4}}=\frac{4}{0}=\infty$$

$$\boxed{\lim_{x\to 2}\frac{x^2-4}{x^3-x^2-x-2}=\infty}$$

4. $\lim\limits_{x\to 1}\dfrac{\sqrt{x+3}-2}{x-1}$, មានរាងមិនកំណត់ $\frac{0}{0}$

$$\frac{\sqrt{x+3}-2}{x-1} \quad \left(\text{មានន័យកាលណា } \mathcal{D}=[-3,+\infty[-\{1\}\right)$$

$$\frac{\sqrt{x+3}-2}{x-1}=\frac{x+3-4}{(x-1)(\sqrt{x+3}+2)}=\frac{x-1}{(x-1)(\sqrt{x+3}+2)}=\frac{1}{\sqrt{x+3}+2}$$
$(x\neq 1)$

$$\lim_{x\to 1}\frac{\sqrt{x+3}-2}{x-1}=\lim_{x\to 1}\frac{1}{\sqrt{x+3}+2}=\frac{1}{4}$$

$$\boxed{\lim_{x\to 1}\frac{\sqrt{x+3}-2}{x-1}=\frac{1}{4}}$$

6 $\lim\limits_{x\to 3}\dfrac{(x-1)-\sqrt{x+1}}{x^2-3x}$, មានរាងមិនកំណត់ $\frac{0}{0}$

$$\frac{(x-1)-\sqrt{x+1}}{x^2-3x} \quad \left(\text{មានន័យលុះត្រាតែ } \mathcal{D}=[-1,+\infty[-\{0,3\}\right)$$

$$=\frac{(x-1)^2-(x+1)}{(x^2-3x)(x-1+\sqrt{x+1})}=\frac{x^2-3x}{(x^2-3x)(x-1+\sqrt{x+1})}, \quad x\neq 0;\ x\neq 3$$

$$=\frac{1}{x-1+\sqrt{x+1}}$$

$$\lim_{x\to 3}\frac{(x-1)-\sqrt{x+1}}{x^2-3x}=\lim_{x\to 3}\frac{1}{x-1+\sqrt{x+1}}=\frac{1}{4}$$

$$\boxed{\lim_{x\to 3}\frac{(x-1)-\sqrt{x+1}}{x^2-3x}=\frac{1}{4}}$$

7. $\lim\limits_{x\to 0}\dfrac{\sqrt{1+x}-\sqrt[3]{1+x}}{x}$; មានរាងមិនកំណត់ $\frac{0}{0}$

$$\frac{\sqrt{1+x}-\sqrt[3]{1+x}}{x}, \quad \text{មានន័យលុះត្រាតែ } \mathcal{D}=]-1,+\infty[-\{0\}$$

$$=\frac{(\sqrt{1+x})^6-(\sqrt[3]{1+x})^6}{x\left[(\sqrt{1+x})^5+(\sqrt{1+x})^4\cdot\sqrt[3]{1+x}+\dots+(\sqrt[3]{1+x})^5\right]}=\frac{N}{D}$$

$$N=(1+x)^3-(1+x)^2=(1+x)^2(1+x-1)=x(1+x)^2$$

$$\frac{N}{D}=\frac{(1+x)^2}{(\sqrt{1+x})^5+(\sqrt{1+x})^4\cdot\sqrt{1+x}+\dots+(\sqrt[3]{1+x})^5}$$

$$\lim_{x\to 0}\frac{\sqrt{1+x}-\sqrt[3]{1+x}}{x}=\lim_{x\to 0}\frac{(1+x)^2}{(\sqrt{1+x})^5+(\sqrt{1+x})^4\sqrt{1+x}+\dots+(\sqrt[3]{1+x})^5}$$

$$\boxed{\lim_{x\to 0}\frac{\sqrt{1+x}-\sqrt[3]{1+x}}{x}=\frac{1}{6}}$$

8. $\lim\limits_{x\to 0}\dfrac{\sqrt{x+1}+\sqrt{x+4}-3}{x}$, មានរាងមិនកំណត់ $\frac{0}{0}$

$\dfrac{\sqrt{x+1}+\sqrt{x+4}-3}{x}$ មាននិយមន័យលុះត្រាតែ $\mathcal{D}=]-1,+\infty[-\{0\}$

$$=\frac{\left(\sqrt{(x+1)}+\sqrt{x+4}\right)^2-9}{x\left[\left(\sqrt{x+1}+\sqrt{x+4}\right)+3\right]}=\frac{x+1+x+4+2\sqrt{(x+1)(x+4)}-9}{x\left[\left(\sqrt{x+1}+\sqrt{x+4}\right)+3\right]}$$

$$=\frac{2x\ \ 4+2\sqrt{(x+1)(x+4)}}{x\left[\left(\sqrt{x+1}+\sqrt{x+4}\right)+3\right]}=\frac{2\left(x-2+\sqrt{(x+1)(x+4)}\right)}{x\left[\left(\sqrt{x+2}+\sqrt{x+4}\right)+3\right]}$$

$$=\frac{2\left[(x-2)^2-(x+1)(x+4)\right]}{x\left[\left(\sqrt{x+1}+\sqrt{x+4}+3\right]\left[(x-2)-\sqrt{(x+1)(x+4)}\right]}$$

$$=\frac{2\left(x^2+4-4x-x^2-4x-x-4\right)}{x\left[\left(\sqrt{x+1}+\sqrt{x+4}+3\right]\left[(x-2)-\sqrt{(x+1)(x+4)}\right]}$$

$$=\frac{-18}{\left[\left(\sqrt{x+1}+\sqrt{x+4}+3\right]\left[(x-2)-\sqrt{(x+1)(x+4)}\right]}\quad x\neq 0$$

$$\lim_{x\to 0}\frac{\sqrt{x+1}+\sqrt{x+4}-3}{x}=\lim_{x\to 0}\frac{-18}{\left[\left(\sqrt{x+1}+\sqrt{x+4}+3\right]\left[(x-2)-\sqrt{(x+1)(x+4)}\right]}$$

$$=\frac{18}{24}=\frac{3}{4}$$

$$\boxed{\lim_{x\to 0}\frac{\sqrt{x+1}+\sqrt{x+4}-3}{x}=\frac{3}{4}}$$

9. $\lim\limits_{x\to 1}\dfrac{\sqrt[3]{x}-1}{\sqrt[3]{4x+4}-2}$ មានរាងមិនកំណត់ $\frac{0}{0}$

$\dfrac{\sqrt[3]{x}-1}{\sqrt[3]{4x+4}-2}$ (មាននិយមន័យលុះត្រាតែ $\mathcal{D}=R-\{-1\}$)

$$=\frac{(x-1)\left[\left(\sqrt[3]{4x+4}\right)^2+2\sqrt[3]{4x+4}+4\right]}{(4x+4-8)\left[\left(\sqrt[3]{x}\right)^2+\sqrt[3]{x}+1\right]}=\frac{(x-1)\left[\left(\sqrt[3]{4x+4}\right)^2+2\sqrt[3]{4x+4}+4\right]}{4(x-1)\left[\left(\sqrt[3]{x}\right)^2+\sqrt[3]{x}+1\right]}$$

$$=\frac{\left(\sqrt[3]{4x+4}\right)^2+2\sqrt[3]{4x+4}+4}{4\left[\left(\sqrt[3]{x}\right)^2+\sqrt[3]{x}+1\right]}\ ,\quad x\neq 1$$

$$\lim_{x\to 1}\frac{\sqrt[3]{x}-1}{\sqrt[3]{4x+4}-2}=\lim_{x\to 1}\frac{\left(\sqrt[3]{4x+4}\right)^2+2\sqrt[3]{4x+4}+4}{4\left[\left(\sqrt[3]{x}\right)^2+\sqrt[3]{x}+1\right]}=\frac{4\times 4\times 4}{4\times 4\times 4}$$

$$=1$$

$$\boxed{\lim_{x\to 1}\frac{\sqrt[3]{x}-1}{\sqrt[3]{4x+4}-2}=1}$$

10. $\lim\limits_{h\to 0}\dfrac{(x+h)^3-x^3}{h}$ មានរាងមិនកំណត់ $\frac{0}{0}$

$$\frac{(x+h)^3-x^3}{h}=\frac{(x+h-x)\left[(x+h)^2+x(x+h)+x^2\right]}{h}$$

$$=\frac{h\left(x^2+2xh+h^2+xh+x^2+x^2\right)}{h}$$

$$=3x^2+3xh+h^2$$

$$\lim_{h\to 0}\frac{(x+h)^3-x^3}{h}=\lim_{h\to 0}3x^2+3xh+h^2=3x^2$$

$$\boxed{\lim_{h\to 0}\frac{(x+h)^3-x^3}{h}=3x^2}$$

II ស្វែងរកលីមីតខាងក្រោម

11 $\lim\limits_{x\to\infty} \dfrac{8x^3+12x^2+x+1}{6x^3+3x^2-5x+2}$; 12 $\lim\limits_{x\to\infty} \dfrac{2x^2-3x+1}{x^3+2x+5}$

13 $\lim\limits_{x\to\infty} \dfrac{3x^2+2x+5}{2x+1}$; 14 $\lim\limits_{|x|\to\infty} \dfrac{\sqrt{x^2-1}}{x}$

15 $\lim\limits_{x\to\infty} \dfrac{x^3-4x^2+5x-1}{2x^3+3x^2-4x+6}$; 16 $\lim\limits_{x\to\infty} \dfrac{x^2+3x-5}{2x^2+1}$

17 $\lim\limits_{x\to\infty} \dfrac{x^3+5x-7}{x^2+3x-1}$, 18 $\lim\limits_{x\to\infty} \dfrac{x+5}{2x^2+3x+7}$

19 $\lim\limits_{x\to\infty} \dfrac{x^4-5x}{x^2-3x+1}$, 20 $\lim\limits_{x\to\infty} \dfrac{1+x-3x^3}{1+x^2+3x^3}$

សំរាយបញ្ជាក់

11 $\lim\limits_{x\to\infty} \dfrac{8x^3+12x^2+x+1}{6x^3+3x^2-5x+2}$, មានរាងមិនកំណត់ $\dfrac{\infty}{\infty}$

$$\frac{8x^3+12x^2+x+1}{6x^3+3x^2-5x+2} = \frac{x^3\left(8+\frac{12}{x}+\frac{1}{x^2}+\frac{1}{x^3}\right)}{x^3\left(6+\frac{3}{x}-\frac{5}{x^2}+\frac{2}{x^3}\right)}$$

$$= \frac{8+\frac{12}{x}+\frac{1}{x^2}+\frac{1}{x^3}}{6+\frac{3}{x}-\frac{5}{x^2}+\frac{2}{x^3}} \; ; \; x \neq 0$$

$$\lim_{x\to\infty} \frac{8x^3+12x^2+x+1}{6x^3+3x^2-5x+2} = \lim_{x\to\infty} \frac{8+\frac{12}{x}+\frac{1}{x^2}+\frac{1}{x^3}}{6+\frac{3}{x}-\frac{5}{x^2}+\frac{2}{x^3}} = \frac{8}{6} = \frac{4}{3}$$

$$\boxed{\lim_{x\to\infty} \frac{8x^3+12x^2+x+1}{6x^3+3x^2-5x+2} = \frac{4}{3}}$$

12. $\lim\limits_{x\to\infty} \dfrac{2x^2-3x+1}{x^3+2x+5}$, មានរាងមិនកំណត់ $\dfrac{\infty}{\infty}$

$$\frac{2x^2-3x+1}{x^3+2x+5} = \frac{x^2\left(1-\frac{3}{x}+\frac{1}{x^2}\right)}{x^3\left(1+\frac{2}{x^2}+\frac{5}{x^3}\right)} = \frac{1-\frac{3}{x}+\frac{1}{x^2}}{x\left(1+\frac{2}{x^2}+\frac{5}{x^3}\right)} \; ; \; x \neq 0$$

$$\lim_{x\to\infty} \frac{2x^2-3x+1}{x^3+2x+5} = \lim_{x\to\infty} \frac{1-\frac{3}{x}+\frac{1}{x^2}}{x\left(1+\frac{2}{x^2}+\frac{5}{x^3}\right)} = 0$$

$$\boxed{\lim_{x\to\infty} \frac{2x^2-3x+1}{x^3+2x+5} = 0}$$

13 $\lim\limits_{x\to\infty} \dfrac{3x^2+2x+5}{2x+1}$, មានរាងមិនកំណត់ $\dfrac{\infty}{\infty}$

$$\frac{3x^2+2x+5}{2x+1} = \frac{x^2\left(3+\frac{2}{x}+\frac{5}{x^2}\right)}{x\left(2+\frac{1}{x}\right)} = \frac{x\left(3+\frac{2}{x}+\frac{5}{x^2}\right)}{2+\frac{1}{x}} \; , \; x \neq 0$$

$$\lim_{x\to\infty} \frac{3x^2+2x+5}{2x+1} = \lim_{x\to\infty} \frac{x\left(3+\frac{2}{x}+\frac{5}{x^2}\right)}{2+\frac{1}{x}} = \infty$$

$$\boxed{\lim_{x\to\infty} \frac{3x^2+2x+5}{2x+1} = \infty}$$

14 $\lim\limits_{|x|\to\infty} \dfrac{\sqrt{x^2-1}}{x}$; មានរាងមិនកំណត់ $\dfrac{\infty}{\infty}$

$\dfrac{\sqrt{x^2-1}}{x}$ មាននិយមន័យលុះត្រាតែ $D =]-\infty,-1] \cup [1,+\infty[$

$$\frac{\sqrt{x^2-1}}{x} = \frac{\sqrt{x^2(1-\frac{1}{x^2})}}{x} = \frac{|x|}{x}\sqrt{1-\frac{1}{x^2}}$$

+ បើ $x>0 \Rightarrow |x| = x$, $\lim\limits_{x\to+\infty}\sqrt{1-\dfrac{1}{x^2}} = 1$

+ បើ $x<0 \Rightarrow |x| = -x$, $\lim\limits_{x\to-\infty}\left(-\sqrt{1-\dfrac{1}{x^2}}\right) = -1$

15 $\lim\limits_{x\to\infty} \dfrac{x^3-4x^2+5x-1}{2x^3+3x^2-4x+6}$ មានរាងមិនកំណត់ $\dfrac{\infty}{\infty}$

$$\frac{x^3-4x^2+5x-1}{2x^3+3x^2-4x+6} = \frac{x^3\left(1-\frac{4}{x}+\frac{5}{x^2}-\frac{1}{x^3}\right)}{x^3\left(2+\frac{3}{x}-\frac{4}{x^2}+\frac{6}{x^3}\right)} = \frac{1-\frac{4}{x}+\frac{5}{x^2}-\frac{1}{x^3}}{2+\frac{3}{x}-\frac{4}{x^2}+\frac{6}{x^3}}$$

$$\lim_{x\to\infty}\frac{x^3-4x^2+5x-1}{2x^3+3x^2-4x+6} = \lim_{x\to\infty}\frac{1-\frac{4}{x}+\frac{5}{x^2}-\frac{1}{x^3}}{2+\frac{3}{x}-\frac{4}{x^2}+\frac{6}{x^3}} = \frac{1}{2}$$

$$\boxed{\lim_{x\to\infty}\frac{x^3-4x^2+5x-1}{2x^3+3x^2-4x+6} = \frac{1}{2}}$$

16 $\lim\limits_{x\to\infty} \dfrac{x^2+3x-5}{2x^2+1}$, មានរាងមិនកំណត់ $\dfrac{\infty}{\infty}$

$$\frac{x^2+3x-5}{2x^2+1} = \frac{x^2\left(1+\frac{3}{x}-\frac{5}{x^2}\right)}{x^2\left(2+\frac{1}{x^2}\right)} = \frac{1+\frac{3}{x}-\frac{5}{x^2}}{2+\frac{1}{x^2}} \quad (x\neq 0)$$

$$\lim_{x\to\infty}\frac{x^2+3x-5}{2x^2+1} = \lim_{x\to\infty}\frac{1+\frac{3}{x}-\frac{5}{x^2}}{2+\frac{1}{x^2}} = \frac{1}{2}$$

$$\boxed{\lim_{x\to\infty}\frac{x^2+3x-5}{2x^2+1} = \frac{1}{2}}$$

17 $\lim\limits_{x\to\infty} \dfrac{x^3+5x-7}{x^2+3x-1}$, មានរាងមិនកំណត់ $\dfrac{\infty}{\infty}$

$$\frac{x^3+5x-7}{x^2+3x-1} = \frac{x^3\left(1+\frac{5}{x^2}-\frac{7}{x^3}\right)}{x^2\left(1+\frac{3}{x}-\frac{1}{x^2}\right)} = \frac{x\left(1+\frac{5}{x^2}-\frac{7}{x^3}\right)}{1+\frac{3}{x}-\frac{1}{x^2}} \quad (x\neq 0)$$

$$\lim_{x\to\infty}\frac{x^3+5x-7}{x^2+3x-1} = \lim_{x\to\infty}\frac{x\left(1+\frac{5}{x^2}-\frac{7}{x^3}\right)}{1+\frac{3}{x}-\frac{1}{x^2}} = \infty$$

$$\boxed{\lim_{x\to\infty}\frac{x^3+5x-7}{x^2+3x-1} = \infty}$$

18 $\lim\limits_{x\to\infty} \dfrac{x+5}{2x^2+3x+7}$, មានរាងមិនកំណត់ $\dfrac{\infty}{\infty}$

$$\frac{x+5}{2x^2+3x+7} = \frac{x\left(1+\frac{5}{x}\right)}{x^2\left(2+\frac{3}{x}+\frac{7}{x^2}\right)} = \frac{1+\frac{5}{x}}{x\left(2+\frac{3}{x}+\frac{7}{x^2}\right)} \quad (x\neq 0)$$

$$\lim_{x\to\infty}\frac{x+5}{2x^2+3x+7} = \lim_{x\to\infty}\frac{1+\frac{5}{x}}{x\left(2+\frac{3}{x}+\frac{7}{x^2}\right)} = 0$$

$$\boxed{\lim_{x\to\infty}\frac{x+5}{2x^2+3x+7} = 0}$$

19 $\lim\limits_{x\to\infty} \dfrac{x^4-5x}{x^2-3x+1}$, មានរាងមិនកំណត់ $\dfrac{\infty}{\infty}$

$$\frac{x^4-5x}{x^2-3x+1} = \frac{x^4\left(1-\frac{5}{x^3}\right)}{x^2\left(1-\frac{3}{x}+\frac{1}{x^2}\right)} = \frac{x^2\left(1-\frac{5}{x^3}\right)}{1-\frac{3}{x}+\frac{1}{x^2}} \quad (x\neq 0)$$

$$\lim_{x\to\infty} \frac{x^4-5x}{x^2-3x+1} = \lim_{x\to\infty} \frac{x^2\left(1-\frac{5}{x^3}\right)}{1-\frac{3}{x}+\frac{1}{x^2}} = +\infty$$

$$\boxed{\lim_{x\to\infty} \frac{x^4-5x}{x^2-3x+1} = +\infty}$$

20. $\lim\limits_{x\to\infty} \dfrac{1+x-3x^3}{1+x^2+3x^3}$ មានរាងមិនកំណត់ $\dfrac{\infty}{\infty}$

$$\frac{1+x-3x^3}{1+x^2+3x^3} = \frac{x^3\left(\frac{1}{x^3}+\frac{1}{x^2}-3\right)}{x^3\left(\frac{1}{x^3}+\frac{1}{x}+3\right)} = \frac{\frac{1}{x^3}+\frac{1}{x^2}-3}{\frac{1}{x^3}+\frac{1}{x}+3} \quad (x\neq 0)$$

$$\lim_{x\to\infty} \frac{1+x-3x^3}{1+x^2+3x^3} = \lim_{x\to\infty} \frac{\frac{1}{x^3}+\frac{1}{x^2}-3}{\frac{1}{x^3}+\frac{1}{x}+3} = -1$$

$$\boxed{\lim_{x\to\infty} \frac{1+x-3x^3}{1+x^2+3x^3} = -1}$$

II ព្យាករណ៍លីមីតការណ៍រួម

21. $\lim\limits_{x\to\pm\infty}\left(\sqrt{x^2-1}-x\right)$; 22 $\lim\limits_{x\to\pm\infty}\left(\sqrt{x^2+3x}-\sqrt{x^2+1}\right)$

23. $\lim\limits_{n\to\infty}\left[\sqrt[3]{m^3-2n^2}-n\right]$; 24. $\lim\limits_{n\to\infty} n\left(\sqrt{n^2+1}-\sqrt{n^2-2}\right)$

25 $\lim\limits_{x\to\infty}\left(\sqrt{ax^2+bx+c}-x\sqrt{a}\right) \quad (a>0)$

26 $\lim\limits_{x\to+\infty}\left(\sqrt[3]{x^3+3x^2}-\sqrt{x^2-2x}\right)$

27 $f(x)=\left(\sqrt{x^2+4x+7}-\sqrt{x^2-4}\right)$ រក $\lim\limits_{x\to\pm\infty} f(x)$

28. $\lim\limits_{x\to\infty}\left(\sqrt[3]{x^3+x+1}-\sqrt[3]{x^3-x-1}\right)$; 29 $\lim\limits_{x\to\infty}\left(\sqrt{x+1}-\sqrt{x}\right)$

30 $\lim\limits_{x\to\infty}\left(\sqrt[3]{x^3+x+1}-\sqrt{x^2-x-1}\right)$

សំរាយបញ្ជាក់

លំហាត់21 $\lim\limits_{x\to\pm\infty}\left(\sqrt{x^2-1}-x\right)$: មានចំលើយ

* $\lim\limits_{x\to-\infty}\left(\sqrt{x^2-1}-x\right) = +\infty+\infty = +\infty$
* $\lim\limits_{x\to+\infty}\left(\sqrt{x^2-1}-x\right)$: លីមីតរាងមិនកំណត់ $\infty-\infty$

ដោយប្រើកន្សោមឆ្លាស់លើនិងក្រោម

$$\lim_{x\to+\infty}\left(\sqrt{x^2-1}-x\right) = \lim_{x\to+\infty} \frac{-1}{\sqrt{x^2-1}+x} = 0$$

ដូចនេះ

$$\boxed{\lim_{x\to\pm\infty}\left(\sqrt{x^2-1}-x\right)=\begin{cases}+\infty & : \text{បើ } x\to-\infty\\ 0 & : \text{បើ } x\to+\infty\end{cases}}$$

22 $\lim\limits_{x\to\pm\infty}\left(\sqrt{x^2+3x}-\sqrt{x^2+1}\right)$, មានរាងមិនកំណត់ $\infty-\infty$

$\sqrt{x^2+3x}-\sqrt{x^2+1}$ មានន័យលុះត្រាតែ $D=\left]-\infty,-3\right]\cup\left[0,+\infty\right[$

$$\sqrt{x^2+3x}-\sqrt{x^2+1}=\frac{\left(\sqrt{x^2+3x}-\sqrt{x^2+1}\right)\left(\sqrt{x^2+3x}+\sqrt{x^2+1}\right)}{\left(\sqrt{x^2+3x}+\sqrt{x^2+1}\right)}$$

$$=\frac{x^2+3x-x^2-1}{\sqrt{x^2+3x}+\sqrt{x^2+1}}=\frac{x-\left(3-\frac{1}{x}\right)}{x^2\left(1+\frac{3}{x}\right)+\sqrt{x^2\left(1+\frac{1}{x^2}\right)}}$$

$$=\frac{x\left(3-\frac{1}{x}\right)}{|x|\left(\sqrt{1+\frac{3}{x}}+\sqrt{1+\frac{1}{x^2}}\right)}$$

* បើ $x>0$ នោះ $|x|=x$

$$\lim_{x\to+\infty}\left(\sqrt{x^2+3x}-\sqrt{x^2+1}\right)=\lim_{x\to+\infty}\frac{x\left(3-\frac{1}{x}\right)}{x\left(\sqrt{1+\frac{3}{x}}+\sqrt{1+\frac{1}{x^2}}\right)}$$

$$=\lim_{x\to+\infty}\frac{3x}{2x}=\frac{3}{2}$$

$$\boxed{\lim_{x\to+\infty}\left(\sqrt{x^2+3x}-\sqrt{x^2+1}\right)=\frac{3}{2}}$$

* បើ $x<0$ នោះ $|x|=-x$

$$\lim_{x\to-\infty}\left(\sqrt{x^2+3x}-\sqrt{x^2+1}\right)=\lim_{x\to-\infty}\frac{x\left(3-\frac{1}{x}\right)}{-x\left(\sqrt{1+\frac{3}{x}}+\sqrt{1+\frac{1}{x^2}}\right)}$$

$$=\lim_{x\to-\infty}\frac{3x}{-2x}=-\frac{3}{2}$$

$$\boxed{\lim_{x\to-\infty}\left(\sqrt{x^2+3x}-\sqrt{x^2+1}\right)=-\frac{3}{2}}$$

23 $\lim\limits_{n\to\infty}\left[\sqrt[3]{n^3-2n^2}-n\right]$ មានរាងមិនកំណត់ $\infty-\infty$

$$\sqrt[3]{n^3-2n^2}-n=\frac{n^3-2n^2-n^3}{\left(\sqrt[3]{n^3-2n^2}\right)^2+n\sqrt[3]{n^3-2n^2}+n^2}$$

$$=\frac{-2n^2}{n^2\left[\sqrt[3]{\left(1-\frac{2}{n}\right)^2}+\sqrt[3]{1-\frac{2}{n}}+1\right]}$$

$$\frac{-2}{\sqrt[3]{\left(1-\frac{2}{n}\right)}+\sqrt[3]{1-\frac{2}{n}+1}}$$

$$\lim_{n\to\infty}\left[\sqrt[3]{n^3-2n^2}-n\right]=\lim_{n\to\infty}\frac{-2}{\sqrt[3]{\left(1-\frac{2}{n}\right)^2}+\sqrt[3]{1-\frac{2}{n}}+1}=-\frac{2}{3}$$

$$\boxed{\lim_{n\to\infty}\left(\sqrt[3]{n^3-2n^2}-n\right)=-\frac{2}{3}}$$

24. $\lim\limits_{n\to\infty} n\left[\sqrt{n^2+1}-\sqrt{n^2-2}\right]$, មានរាងមិនកំណត់ $\infty-\infty$

$$n\left[\sqrt{n^2+1}-\sqrt{n^2-2}\right]=\frac{n[(n^2+1)-(n^2-2)]}{\sqrt{n^2+1}+\sqrt{n^2-2}}=\frac{n(n^2+1-n^2+2)}{\sqrt{n^2+1}+\sqrt{n^2-2}}$$

$$=\frac{3n}{n\left(\sqrt{1+\frac{1}{n^2}}+\sqrt{1-\frac{2}{n^2}}\right)}=\frac{3}{\sqrt{1+\frac{1}{n^2}}+\sqrt{1-\frac{2}{n^2}}}\quad (n\neq 0)$$

$$\lim_{n\to\infty} n\left[\sqrt{n^2+1}-\sqrt{n^2-2}\right]=\lim_{n\to\infty}\frac{3}{\sqrt{1+\frac{1}{n^2}}+\sqrt{1-\frac{2}{n^2}}}=\frac{3}{2}$$

$$\boxed{\lim_{n\to\infty} n\left[\sqrt{n^2+1}-\sqrt{n^2-2}\right]=\frac{3}{2}}$$

25. $\lim\limits_{x\to\infty}\left(\sqrt{ax^2+bx+c}-x\sqrt{a}\right)$ $(x>0)$ មានរាងមិនកំណត់ $\infty-\infty$

$$\sqrt{ax^2+bx+c}-x\sqrt{a}=\frac{ax^2+bx+c-ax^2}{\sqrt{ax^2+bx+c}+x\sqrt{a}}=\frac{bx+c}{x\left(\sqrt{a+\frac{b}{x}+\frac{c}{x^2}}+\sqrt{a}\right)}$$

$$=\frac{b+\frac{c}{x}}{\sqrt{a+\frac{b}{x}+\frac{c}{x^2}}+\sqrt{a}}\qquad x\neq 0$$

$$\lim_{x\to\infty}\left(\sqrt{ax^2+bx+c}-x\sqrt{a}\right)=\lim_{x\to\infty}\frac{b+\frac{c}{x}}{\sqrt{a+\frac{b}{x}+\frac{c}{x^2}}+\sqrt{a}}=\frac{b}{2\sqrt{a}}$$

$$\boxed{\lim_{x\to\infty}\left(\sqrt{ax^2+bx+c}-x\sqrt{a}\right)=\frac{b}{2\sqrt{a}}}$$

លំហាត់ទី 26

$\lim\limits_{x\to+\infty}\left(\sqrt[3]{x^3+3x^2}-\sqrt{x^2-2x}\right)$ មានរាងមិនកំណត់ $\infty-\infty$

រំលឹក $a^6-b^6=(a-b)(a^5-a^4b+a^3b^2+a^2b^3+ab^4+b^5)$

$$\sqrt[3]{x^3+3x^2}-\sqrt{x^2-2x}=\frac{(x^3+3x^2)^2-(x^2-2x)^3}{\sqrt[3]{(x^3+3x^2)^5}+\sqrt[3]{(x^3+3x^2)^4}\cdot\sqrt{x^2-2x}+\dots+\sqrt{(x^2-2x)^5}}$$

$$=\frac{N}{D}$$

$$N=(x^3+3x^2)^2-(x^2-2x)^3$$

$$=x^6+9x^4+6x^5-(x^6-6x^5+12x^4-8x^3)$$

$$=12x^5-3x^4+8x^3=x^5\left(12-\frac{3}{x}+\frac{8}{x^2}\right)$$

$$D=x^5\left[\sqrt{\left(1+\frac{3}{2}\right)^5}+\sqrt[3]{\left(1+\frac{3}{x}\right)^4}\cdot\sqrt{1-\frac{2}{x}}+\dots+\sqrt{\left(1-\frac{2}{x}\right)^5}\right]$$

$$\frac{N}{D}=\frac{\left(12-\frac{3}{x}+\frac{8}{x^2}\right)}{\sqrt{\left(1+\frac{3}{x}\right)^5}+\sqrt{\left(1+\frac{3}{x}\right)^4}\cdot\sqrt{1-\frac{2}{x}}+\dots+\sqrt{\left(1-\frac{2}{x}\right)^5}}$$

$$\lim_{x\to+\infty}\left(\sqrt[3]{x^3+3x^2}-\sqrt{x^2-2x}\right)$$

$$=\lim_{x\to+\infty}\frac{12-\frac{3}{x}+\frac{8}{x^2}}{\sqrt{\left(1+\frac{3}{x}\right)^5}+\sqrt{\left(1+\frac{3}{x}\right)^4}\cdot\sqrt{1-\frac{2}{x}}+\quad+\sqrt{\left(1-\frac{2}{x}\right)^5}}$$

$$=\frac{12}{6}=2$$

$$\boxed{\lim_{x\to+\infty}\left(\sqrt[3]{x^3+3x^2}-\sqrt{x^2-2x}\right)=2}$$

លំហាត់ 27

$$\lim_{x\to\pm\infty}\left(\sqrt{x^2+4x-7}-\sqrt{x^2-4}\right)$$ លីមីតនេះមានរាងមិនកំណត់ $\infty-\infty$

គេអាចប្រើកន្សោមឆ្លាស់ដើម្បីគណនា

$$\lim_{x\to\pm\infty}\left(\sqrt{x^2+4x+7}-\sqrt{x^2-4}\right)=\lim_{x\to\pm\infty}\frac{4x+11}{\sqrt{x^2+4x+7}+\sqrt{x^2-4}}$$

$$=\lim_{x\to\pm\infty}\frac{4x+11}{|x|\sqrt{1+\frac{4}{x}+\frac{7}{x^2}}+|x|\sqrt{1-\frac{4}{x^2}}}$$

$$=\lim_{x\to\pm\infty}\frac{4x+11}{|x|\left(\sqrt{1+\frac{4}{x}+\frac{7}{x^2}}+\sqrt{1-\frac{4}{x^2}}\right)}$$

* បើ $x\to+\infty$ នោះ $|x|=x$

បើ $x\to-\infty$ នោះ $|x|=-x$ ដូចនេះគេបាន

$$\lim_{x\to\pm\infty}\left(\sqrt{x^2+4x+7}-\sqrt{x^2-4}\right)=\lim_{x\to\pm\infty}\frac{4x+11}{|x|\left(\sqrt{1+\frac{4}{x}+\frac{7}{x^2}}+\sqrt{1-\frac{4}{x^2}}\right)}$$

$$=\lim_{x\to\pm\infty}\frac{4x+11}{\pm x\left(\sqrt{1+\frac{4}{x}+\frac{7}{x^2}}+\sqrt{1-\frac{4}{x^2}}\right)}$$

$$=\lim_{x\to\pm\infty}\frac{4+\frac{11}{x}}{\pm\left(\sqrt{1+\frac{4}{x}+\frac{7}{x^2}}+\sqrt{1-\frac{4}{x^2}}\right)}$$

$$=\frac{4}{\pm 2}=\pm 2$$

$$\boxed{\lim_{x\to\pm\infty}\left(\sqrt{x^2+4x+7}-\sqrt{x^2-4}\right)=\pm 2}$$

28. $\lim_{x\to\infty}\left(\sqrt[3]{x^3+x+1}-\sqrt[3]{x^3-x-1}\right)$ មានរាងមិនកំណត់ $\infty-\infty$

$$\sqrt[3]{x^3+x+1}-\sqrt[3]{x^3-x-1}=\frac{x^3+x+1-x^3+x+1}{\sqrt[3]{(x^3+x+1)^2}+\sqrt[3]{x^3+x+1}\cdot\sqrt[3]{x^3-x-1}+\sqrt[3]{(x^3-x-1)^2}}$$

$$=\frac{2x+2}{\sqrt[3]{\left[x^3\left(1+\frac{1}{x^2}+\frac{1}{x^3}\right)\right]^2}+\sqrt[3]{x^3\left(1+\frac{1}{x^2}+\frac{1}{x^3}\right)}\cdot\sqrt[3]{x^3\left(1-\frac{1}{x^2}-\frac{1}{x^3}\right)}+\dots}$$

